**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២០០៤ ព.ណ.ន.ជំពាក៣

ថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំមមីសប្តស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំវេទិកាពាណិជ្ជកម្មឌីជីថលកម្ពុជា និងពិព័រណ៍អនឡាញ លើកទី៣
(The 3rd Cambodia Digital Trade Forum and Online Expo)

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបដំណឹងដល់ **លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន ម្ចាស់ក្រុមហ៊ុន និងសាធារណជនទាំងអស់** ជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងរៀបចំ **«វេទិកាពាណិជ្ជកម្មឌីជីថលកម្ពុជា និងពិព័រណ៍អនឡាញ លើកទី៣ (The 3rd Cambodia Digital Trade Forum and Online Expo)»** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១-១៣ ខែកញ្ញា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ (អគារ G-L) រាជធានីភ្នំពេញ ក្នុងគោលបំណងជំរុញកិច្ចពិភាក្សាអំពីទិដ្ឋភាពពាណិជ្ជកម្មឌីជីថល ក្របខ័ណ្ឌគោលនយោបាយ ការផ្សព្វផ្សាយ និងជំរុញការនាំចេញផលិតផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការជំរុញការប្រើប្រាស់ថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុក និងអន្តរជាតិ ជាពិសេសថ្នាល CambodiaTrade.com របស់ក្រសួងពាណិជ្ជកម្ម។ ជាមួយគ្នានេះ **លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធវេទិកាខាងលើជាផ្លូវការ នារសៀលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៦ ផងដែរ។

ព្រឹត្តិការណ៍ខាងលើនឹងមាន៖ ១-ការថ្លែងសុន្ទរកថាគន្លឹះ៖ ព្រមទាំងកិច្ចសន្ទនាកម្រិតថ្នាក់ដឹកនាំ ការបង្ហាញប្រព័ន្ធអេកូឡូស៊ីរបស់ក្រុមហ៊ុន Apple និងបញ្ញាសិប្បនិម្មិត (AI) សន្តិសុខសាយប័រនិងទំនុកចិត្តឌីជីថល ភស្តុភារកម្មឆ្លងកាត់ព្រំដែន, ២-វេទិកាស្ត្រីក្នុងវិស័យពាណិជ្ជកម្មឌីជីថល, ៣-កម្មវិធីបង្កើនសមត្ថភាពនិងភាពអង់អាចរបស់យុវជនតាមរយៈការជជែកដេញដោល និងកម្មវិធីប្រកួតប្រជែងជាក្រុម (Hackathon), និង៤-ការរៀបចំស្តង់តាំងបង្ហាញផលិតផល និងសេវាកម្មឌីជីថលជាច្រើនប្រភេទរួមមាន៖ ផលិតផលកម្ពុជា #MadeInCambodia ផលិតផលស្ត្រី #MadeByHer ផលិតផលសម្គាល់ភូមិសាស្ត្រ ផលិតផលម៉ាកសមូហភាព អាហារនិងភេសជ្ជៈ សេវាកម្មអ៊ីនធឺណែត ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ធនាគារ ភ្នាក់ងារដឹកជញ្ជូន សេវាកម្មក្លោដ និង AI ជាដើម។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម **សូមអញ្ជើញ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន ម្ចាស់ក្រុមហ៊ុន និងសាធារណជន** ដែលមានបំណងចូលរួមតាំងបង្ហាញផលិតផល និងសេវាកម្មក្នុងព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញបំពេញបែបបទស្នើសុំចូលរួមតាមរយៈ QR Code ខាងក្រោម **ឱ្យបានមុនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៦** ជាកំណត់។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្មលេខ ១២៦៦ ឬតាមរយៈអ៊ីម៉ែល៖chao.katphouy@moc.gov.kh។

**សូមអរគុណ!**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469